**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការកែសម្រួលលើ មាត្រា៤ ចំណុច ៤.១ នៃអនុក្រឹត្យ លេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខនស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៦/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបញ្ចប់តំណែងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និង សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៧អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បកចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០០៦ ស្តីពី ការកែសម្រួល

មាត្រា១ នៃអនុក្រឹត្យ លេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- អនុលោមតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១.-**

ត្រូវបានកែសម្រួលលើមាត្រា៤ ត្រង់ចំណុច ៤.១ និងកែសម្រួលពាក្យ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ដូចតទៅ ÷

**មាត្រា៤ ចំណុច៤.១ថ្មី**

-គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេសៈ

គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស មានភារកិច្ចដោះស្រាយជាបន្ទាន់នូវរាល់កិច្ចការទាំងឡាយដែលកើតមាននៅតាមតំបន់សេដ្ឋកិច្ចពិសេសទាំងលើទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពច្បាប់ ឬដែលមានលក្ខណៈស្ថិតក្នុងសមត្ថកិច្ចចម្រុះត្រូវដោះស្រាយដោយអន្តរក្រសួង ឬអន្តរស្ថាប័ន ហើយដែលហួសពីលទ្ធភាពសម្រេចរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ឬរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

ក្រៅពីនោះគណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេសក៏ទទួលភារកិច្ច ជាយន្តការទទួលពាក្យតវ៉ា និងដោះស្រាយសំណើតវ៉ានោះ ពីសំណាក់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ផងដែរ។

គណៈកម្មាធិការនេះ មានទីតាំងនៅទីស្នាក់ការក្រុមប្រឹក្សា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាក្នុងកិច្ចការងាររបស់ខ្លួន។

សមាសភាពរបស់គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេសមានដូចតទៅ ÷

| | | |
|---|---|---|
| ១- | ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាប្រធាន |
| ២- | រដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- | រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- | រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម | សមាជិក |
| ៥- | រដ្ឋមន្ត្រីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៧- | រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួង សាធារណៈការ និងដឹកជញ្ជូន | សមាជិក |

៩- រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១០- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១១- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ជាលេខាធិការ

ក្នុងករណីចាំបាច់ គណៈកម្មាធិការនេះអាចអញ្ជើញ សមាជិកណាមួយនៃក្រុមប្រឹក្សា ដើម្បីចូលរួមប្រជុំ នៅរាល់កិច្ចប្រជុំរបស់គណៈកម្មាធិការនេះ ។ សម័យប្រជុំរបស់គណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេសប្រព្រឹត្តទៅ តាមការកោះអញ្ជើញប្រជុំរបស់លេខាធិការរបស់គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស ផ្អែកតាមការកំណត់ណែនាំរបស់ប្រធាននៃគណៈកម្មាធិការនេះ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលគ្រប់ខេត្តក្រុង និងអង្គភាពពាក់ព័ន្ធត្រូវទទួលអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋលេខាធិការទី១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គង់ វិបុល**

**ហ៊ុន សែន**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ